# របាយការណ៍សង្ខេប

# របស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម ឆ្នាំ២០១៩

២៦ មិថុនា ២០១៩

# ១. សារបានជំងឺគ្រុនឈាម

ជំងឺគ្រុនឈាមរបស់មនុស្ស គឺជាជំងឺបង្កឡើងដោយវីរុសគ្រុនឈាមចូលទៅក្នុងខ្លួនមនុស្សតាមរយៈការខាំរបស់សត្វមូសខ្លាញី (ប្រភេទ ***អាអេដែស អាអេជីបតាយ*** ឬ ***អាអេដែស អាល់បូភីកទីស***) មានផ្ទុកវីរុសគ្រុនឈាមទៅមនុស្ស។ សត្វមូសខ្លាចូលចិត្តខាំបឺតឈាមក្នុងអំឡុងពេលថ្ងៃ (ពីពេលព្រឹកព្រលឹមអុល រហូតដល់ពេលប្រលប់)។ កត្តាដែលទាក់ទាញមូសខាំមនុស្សដោយសារតែ ក្លិនញើសមានក្លិនអាម៉ូញាក់ និងអាស៊ីតឡាក់ទិក ក្លិនកាបោនឌីអុកស៊ីតតាមខ្យល់ដង្ហើមរបស់មនុស្ស ពណ៌ខ្មៅ ឬងងឹតៗជាដើម។ វីរុសគ្រុនឈាមស្ថិតក្នុង***អំបូរហ្លាវីវីរុស*** ដែលមាន៤ប្រភេទសេរ៉ូទីបផ្សេងគ្នាគឺ DENV-1, DENV-2, DENV-3 និង DENV-4។ គួរកត់សំគាល់ផងដែរថាមនុស្សយើងក្រោយពីបានជាសះស្បើយដោយសារជំងឺគ្រុនឈាមប្រភេទសេរ៉ូទីបណាមួយហើយ គឺអ្នកនោះនឹងមានប្រព័ន្ធការពារខ្លួនលើជំងឺគ្រុនឈាមប្រភេទសេរ៉ូទីបនោះអស់មួយជីវិត ប៉ុន្តែអ្នកនោះនឹងអាចកើតជំងឺគ្រុនឈាមប្រភេទសេរ៉ូទីបផ្សេងទៀតដោយសារតែប្រព័ន្ធការពារសំរាប់ប្រភេទសេរ៉ូទីបផ្សេងទៀតមានលក្ខខណៈមិនពេញលេញ និងមានរយៈពេលខ្លី។ រោគសញ្ញា និងសញ្ញាណគ្លីនិកជំងឺគ្រុនឈាម គឺ ក្តៅខ្លួនខ្លាំងភ្លាមៗ (38.5°c+) និងអាចអមដោយ មុខស្លូតក្រហម ភ្នែកក្រហម ងោកងួយដេក ឈឺក្បាល ឈឺសាច់ដុំ ឈឺសន្លាក់ ឈឺពោះ កុមារយំ កន្ទួលក្រហមលើស្បែក ជាំខ្មៅស្បែកដុំៗចេញឈាម ឡេះឡះ។ល។

ជំងឺគ្រុនជាជំងឺមួយដែលជាគេមិនបានចាត់ចូលជាប្រភេទជំងឺស្ថិតក្នុងការទទួលបន្ទុករបស់ដៃគូវិនិយោគណាមួយនៅឡើយនោះទេលើពិភពលោក បើទោះជា ជំងឺគ្រុនឈាមគឺជាបញ្ហាកង្វល់អាទិភាពក្នុងសុខភាពសារធារណៈពិភពលោក ក៏ដូចជាតំបន់ត្រូពិក រួមទាំងប្រទេសកម្ពុជាផងដែរ។

ពិភពលោកប្រជាជនប្រមាណជា ៣,៩Billion នាក់បានរស់នៅក្នុងតំបន់ប្រឈមជំងឺគ្រុនឈាមនៃ ១២៨ ប្រទេស ដែលក្នុងនោះ ប្រមាណជា ៣៩០លានករណី បានទទួល មេរោគគ្រុនឈាម និងក្លាយជាឈឺមានរោគសញ្ញា ឬសញ្ញាណគ្លីនិក ប្រមាណជា ៩៦លានករណី (*Ref. WHO, 15 April 2019*)។

ប្រទេសកម្ពុជា គឺ ជំងឺគ្រុនឈាម ជាបញ្ហាសុខភាពសារធារណៈមួយដែលត្រូវបានក្រសួងសុខាភិបាលចាត់ទុកថាជាជំងឺអាទិភាព។ ករណីជំងឺប្រចាំឆ្នាំ មានប្រមាណជាង ១០.០០០ករណីឈឺក្នុងមួយឆ្នាំៗ និងជាង ៥០០នាក់ស្លាប់ក្នុងអំឡុងទសវត្សឆ្នាំ៨០ រួចបន្តធ្លាក់ចុះមកនៅទាបបំផុតនាឆ្នាំចុងក្រោយ ដោយ អត្រាស្លាប់ទាបជាង ០,៥%។ ករណីជំងឺបានរាតត្បាតខ្លាំងរាល់ ៥ - ៦ ឆ្នាំម្តង ឬ ១០ - ១២ឆ្នាំម្តង គឺនៅឆ្នាំ១៩៩៨ (មាន១៦.២៦០ករណី/៤៧៤នាក់ស្លាប់) ឆ្នាំ២០០៧ (មាន៣៩.៨៥១ករណី/៤០៧នាក់ស្លាប់) និងឆ្នាំ ២០១២ (មាន៤២.៣៦២ករណី/១៨៩នាក់ស្លាប់)។




*Figure-1: Dengue distribution in Cambodia by the reporting system, 1980-2018*

តាមការវិភាគដើម្បីប៉ាន់ប្រមាណសន្ទស្សន៍ជំងឺគ្រុនឈាមនៅប្រទេសកម្ពុជា គឺកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម បានប្រើវិធីសាស្រ្តគំរូគណនាស្ថិតិបែបវិទ្យាសាស្រ្ត ARIMA បង្ហាញអោយឃើញថាស្ថានភាពជំងឺគ្រុនឈាមឆ្នាំ២០១៩ នឹងអាចកើតមានប្រមាណជា ៥០,០០០ ករណី។ កត្តាជំរុញអោយជំងឺគ្រុនឈាមកើនឡើងនេះ គឺអាចទាក់ទងជាមួយ កត្តាអាកាសធាតុប្រែប្រួល កត្តាវីរុស កត្តាភ្នាក់ងារសត្វមូស កត្តាភាពស៊ាំរបស់ប្រព័ន្ធការពារមនុស្ស កត្តាចរាចរ និងកត្តាវត្ថុស្តុក ឬដក់ទឹក ជាដើម។ កត្តាអាកាសធាតុ (El-Nino) បានបង្ហាញពីទំនាក់ទំនងនៃរដូវភ្លៀងនឹងបង្កើនស្ថានភាពជំងឺគ្រុនឈាម ២ដងច្រើនជាងរដូវប្រាំង ឯសីតុណ្ហភាពកើនឡើង ១អង្សារសេ នឹងបង្កើនជំងឺគ្រុនឈាម ៣០% ឯកំពស់ទឹកភ្លៀងកើន ១ ម.ម នឹងបង្កើនជំងឺគ្រុនឈាម ១១% និងភ្លៀងប្រចាំថ្ងៃនឹបង្កើនជំងឺគ្រុនឈាម ៨%។ កត្តាអាកាសធាតុក្តៅកើនឡើងបានជំរុញល្បឿនវីរុសបំពេញសមត្ថភាពបង្ករោគឆាប់ពេញលេញនៅក្នុងខ្លួនសត្វមូស និងវដ្តសត្វមូសកកើតបានលឿន។ កត្តាសង្គមអភិវឌ្ឍន៍ និងសកលភាវូបនីយកម្ម បានចូលរួមចំនែកយ៉ាងសកម្មជាមួយការកកើតដង់ស៊ីតេ និងការចំលងរបស់ភ្នាក់ងារចំលង តាមរយៈការចល័តរហ័សរបស់មនុស្សនិងភ្នាក់ងារចំលង គមនាគមន៍និងដឹកជញ្ជូនរហ័សល្អ ការគ្រប់គ្រងកាកសំណល់នៅមានកំរិត ភាពបរិបូរណ៍នៃវត្ថុស្តុក ឬដក់ទឹក (ពាង អាង សំបកកង់យាន្តជំនិះ ធុង ប៉ោត ក្រឡ ចាន កំប៉ុង ដប កែវ និងការដ្ឋានសំណង់ ជាដើម)។ គួរកត់សំគាល់ថា សំបកកង់យាន្តជំនិះ ជាប្រភពទាក់ទាញសត្វមូសខ្លាទៅពងបង្កបង្កើតកូនចៅជាងកន្លែងទៀត១១ដង។




| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec | **Total** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **Forecasted** | 1814 | 868 | 1149 | 1437 | 3796 | 8901 | 12088 | 9514 | 4831 | 2948 | 1571 | 803 | **49426** |
| **Observed** | 2219 | 1650 | 2092 | 3060 | 3161 | | | | | | | | |

*Figure-2: ARIMA-forecasted Dengue burden in 2019*

# ២. ស្ថានភាពជំងឺគ្រុនឈាមក្នុងឆ្នាំ២០១៩

## ២.១. ស្ថានភាពជំងឺគ្រុនឈាមឆ្នាំ២០១៩ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

តំបន់**អាស៊ីប៉ាស៊ីហ្វិក** គឺស្ថានភាពជំងឺគ្រុនឈាមឆ្នាំ ២០១៩ កំពុងមានការកើនឡើងគួរអោយកត់សំគាល់ ពី ២ ទៅ ៥ដងច្រើនជាងឆ្នាំ ២០១៨ ក្នុងអំឡុងពេលដូចគ្នាចាប់ពីខែ មករា - ២៣ ឧសភា។ ប្រទេសម៉ាឡេស៊ី មានជាង៤៦០០០ករណី/៧៤នាក់ស្លាប់ ប្រទេសហ្វីលីពីន មានជាង៧២.០០០ករណី/៣០៣នាក់ស្លាប់ ប្រទេសសិង្ហបុរីមាន ៣.២៣៣ករណី/គ្មានស្លាប់ ប្រទេសវៀតណាមមានជិត ៦០.០០០ករណី/០៤នាក់ស្លាប់ ប្រទេសឡាវមាន៣១៨៨ករណី/០៩នាក់ស្លាប់ ប្រទេសចិនមាន ៥២ករណី/na និងប្រទេសអូស្រ្តាលីមាន៤៦១ករណី។

## ២.២. ស្ថានភាពជំងឺគ្រុនឈាមឆ្នាំ២០១៩ ក្នុងប្រទេសកម្ពុជា

ជំងឺគ្រុនឈាមក្នុងរយៈពេលពីខែ មករា - មិថុនា (គិតត្រឹមសប្តាហ៏ទី២១) ក្នុងឆ្នាំ២០១៩ មានចំនួនសរុប១៣.៨៤៣ករណី/២៤នាក់ស្លាប់ (អត្រាស្លាប់ ០,២%) បានន័យថា ប្រហែល៥ដងកើនឡើងច្រើនជាងឆ្នាំ២០១៨ដែលមានតែ ២.៥៣០ករណី/០៧នាក់ស្លាប់។




*Figure-3: Dengue cases by week in Cambodia 2019*

ស្ថានភាពជំងឺឆ្នាំ ២០១៩ នេះកំពុងមានកំនើនប្រចាំខែច្រើនជាងឆ្នាំ ២០១២ តែអត្រាស្លាប់ឆ្នាំ ២០១២ មាន 0,៤% (៥0នាក់ស្លាប់) សន្ទុះកំណើនប្រចាំខែហាក់យឺតជាងឆ្នាំ២០១២ (គឺឆ្នាំ២០១៩ កើន៦៥៨ករពី/ខែ តែឆ្នាំ២០១២កើន១៥៤៩ករណី/ខែ)។




*Figure-4: Dengue cases and CFR by month in Cambodia between 2012 with 2019*

ខេត្តដែលមានភូមិសាស្រ្តជំងឺគ្រុនឈាមច្រើនជាងគេ គឺ រាជធានីភ្នំពេញ ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តព្រះសីហនុ។ ករណីស្លាប់មកពី ១៥ រាជធានី-ខេត្ត ដូចមានក្នុងតារាងខាងក្រោម។

*Table-1: High burden of Dengue cases and deaths by province in Cambodia 2019*

| Province | Cases | Deaths | Representativeness |
|---|---|---|---|
| Phnom Penh | 1913 | 2 | 15.70 |
| KampongThom | 1594 | 1 | 13.08 |
| Siem Reap | 1526 | 2 | 12.53 |
| Kandal | 1174 | 2 | 9.64 |
| Kampong Cham | 865 | 2 | 7.10 |
| Battambang | 623 | 3 | 5.11 |
| B.Meanchey | 538 | 0 | 4.42 |
| K.Pr.Sihaknouk | 462 | 3 | 3.79 |
| KampongSpeu | 433 | 1 | 3.55 |
| PreahVihear | 422 | 1 | 3.46 |
| O.Meanchey | 401 | 0 | 3.29 |
| PreyVeng | 399 | 1 | 3.28 |
| Tbongkhmum | 267 | 2 | 1.9 |
| Kratie | 257 | 3 | 1.8 |
| Paillin | 178 | 1 | 1.3 |




*Figure-5: Dengue incidence and CFR by province between 2018 vs 2019*

ស្ថានភាពជំងឺបានកើនឡើងគ្រប់រាជធានីខេត្ត នៅឆ្នាំ ២០១៩នេះ បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៨ ប៉ុន្តែមិនមែនបានន័យថា ជំងឺគ្រុនឈាមមានទូទាំងផ្ទៃប្រទេសនោះទេ គឺកើតមានរាយប៉ាយដុំៗ តាមភូមិសាស្ត្រភូមិ នៃឃុំ/សង្កាត់។ សកម្មភាពអន្តរាគមន៍ត្រូវបានអនុវត្តន៍ជាបន្តបន្ទាប់តាមយុទ្ធសាស្ត្រជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមចាប់តាំងពីដើមខែឧសភារហូតមកដល់បច្ចុប្បន្ន។ ជាគោលការណ៍ ស្ថានភាពនៃជំងឺនឹងអាចចាប់ផ្តើមវាយតំលៃស្ថានភាពប្រែប្រួលបានបន្ទាប់ពី ៣០ ថ្ងៃ ក្រោយនៃប្រសិទ្ធពលកិច្ចអន្តរាគមន៍លើទីតាំងនោះជាបន្តបន្ទាប់។ តាមការវិភាគឃើញថា ចាប់អាទិត្យទី ២០ - ២១ គឺល្បឿនកំណើនជំងឺគ្រុនឈាមបានថយចុះនៅ ៦ខេត្ត (កំពង់ធំ កែប កំពង់ស្ពឺ ព្រះវិហារ ព្រៃវែង និងក្រចេះ) ឬក៏នៅបេរចំនួន ៧ខេត្ត (ត្បូងឃ្មុំ ពោធិសាត់ ឧត្តរមានជ័យ ភ្នំពេញ សៀមរាប តាកែវ និងមណ្ឌលគីរី)។ ចំពោះខេត្តដែលមិនទាន់ថយចុះ គឺអាចដោយទីតាំងនោះ ទើបតែបានអន្តរាគមន៍ ឬក៏មានទីតាំងខ្លះត្រូវពិនិត្យតាមដានបន្តថាជាទីតាំងថ្មី ឬយ៉ាងណា?។

| PROCODE | PROVINCES | Population | W1-19 | W20 | W21 | Improved for 20-21 |
|---|---|---|---|---|---|---|
| 3 | Kampong Cham | 1,393,385 | 763 | 102 | 71 | **-31** |
| 23 | Kep | 47,480 | 38 | 31 | 1 | **-30** |
| 5 | KampongSpeu | 963,062 | 377 | 56 | 33 | **-23** |
| 13 | PreahVihear | 197,569 | 348 | 74 | 63 | **-11** |
| 14 | PreyVeng | 1,485,160 | 342 | 57 | 49 | **-8** |
| 10 | Kratie | 397,582 | 218 | 22 | 17 | **-5** |
| 25 | TboungKhmum | 1,041,036 | 201 | 34 | 32 | **-2** |
| 15 | Pursat | 537,031 | 70 | 9 | 8 | **-1** |
| 22 | O.Meanchey | 201,224 | 358 | 43 | 44 | **1** |
| 12 | Phnom Penh | 1,396,516 | 1798 | 115 | 117 | **2** |
| 17 | Siem Reap | 1,082,949 | 1362 | 164 | 166 | **2** |
| 21 | Takeo | 1,229,245 | 100 | 16 | 18 | **2** |
| 11 | MondulKiri | 66,053 | 90 | 62 | 65 | **3** |

*Figure-6: Status of Dengue incidence improvement by province*

ជំងឺគ្រុនឈាម កើតលើគ្រប់ភេទស្រីប្រុស ទាំងក្មេងទាំងចាស់។ ក្រុមអាយុប្រឈមកើតជំងឺគ្រុនឈាមច្រើនជាងគេ គឺ ក្រុមអាយុ ៥ - ១៤ ឆ្នាំ ប៉ុន្តែអត្រាស្លាប់ខ្ពស់លើក្រុមអាយុកាន់តែក្មេង ពិសេសក្រុមអាយុតិចជាង ៥ឆ្នាំ (៩នាក់ស្លាប់)។ ក្រុមអាយុ ១៥ឆ្នាំឡើង គឺកំពុងមានកំណើនជាងឆ្នាំមុនៗ តែមិនមានស្លាប់ទេ បានន័យថានេះក៏ជាសញ្ញាណមួយប្រាប់យើងថា ប្រទេសអភិវឌ្ឍន៍កាន់តែប្រសើរជឿនលឿន គឺក្រុមអាយុគ្រុនឈាមនឹងប្រែប្រួលផ្លាស់ប្តូរពីក្រុមអាយុក្មេងទៅក្រុមអាយុពេញវ័យឡើងទៅ (នេះទំនាក់ទំនងទៅនឹងការយល់ដឹងរបស់ប្រជាជនដែលបង្ការការចំលងបានរួចផុតកាលពីនៅអាយុវ័យក្មេង)។




*Figure-7: Dengue risky age group and sex in Cambodia 2019*

ករណីជំងឺស្លាប់ទាំង ២៤នាក់ ក្នុងឆ្នាំ ២០១៩ នេះ គឺសុទ្ធតែជាករណីដែលបានមកស្លាប់នៅមន្ទីរពេទ្យថ្នាក់ជាតិ ឬថ្នាក់ខេត្ត (បានន័យថាជាមន្ទីរពេទ្យមានសមត្ថភាព និងគុណភាពសេវាល្អខ្ពស់) ដោយសារតែចូលមកទទួលសេវាយឺតយ៉ាវពេលវេលា និងស្ថានភាពជំងឺបានវិវត្តទៅជាធ្ងន់ធ្ងររួចខ្លាំងពេកដល់ដំណាក់កាលចុងក្រោយ រួមផ្សំជាមួយផលវិបាកដែលទទួលឥទ្ធិពលមកពីការទទួលសេវាព្យាបាលក្នុងអំឡុង ៤ - ៦ថ្ងៃដំបូងមិនបានត្រឹមត្រូវដោយសារតែគ្រួសារអ្នកជំងឺព្យាយាម**<u>ព្យាបាលដោយខ្លួនឯង លេបថ្នាំមិនត្រឹមត្រូវគ្មានវេជ្ជបញ្ជា ឬពន្យាពេលនៅទទួលសេវាព្យាបាលសេវាឯកជនខ្លះដែលគ្មានសមត្ថភាពវិជ្ជាជីវៈត្រឹមត្រូវ</u>**ក្នុងការធ្វើរោគវិនិច្ឆ័យ ព្យាបាល និងថែទាំជំងឺគ្រុនឈាម។ អ្នកជំងឺបានស្លាប់នៅមន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ ១២នាក់ មន្ទីពេទ្យពេទ្យជ័យវរ្ម័ន ២នាក់ មន្ទីរពេទ្យកុមារជាតិ ២នាក់ និងមន្ទីរពេទ្យខេត្ត ៨នាក់។ **ចូរចងចាំថា** ជំងឺគ្រុនឈាម **<u>គ្មានថ្នាំពិសេសណាសំរាប់សំលាប់វីរុសគ្រុនឈាមបាននៅឡើយនោះទេ</u>** ហើយនឹង**<u>ប្រឈមបាត់បង់អាយុជីវិតគ្រប់ពេល ប្រសិនបើគ្មានការពិនិត្យព្យាបាល និងថែទាំត្រឹមត្រូវ ឬក៏មិនមកទទួលសេវាត្រឹមត្រូវរបស់រដ្ឋ</u>** (មណ្ឌលសុខភាព និងមន្ទីរពេទ្យដែលនៅជិតបំផុត) បានទាន់ពេលក្នុងអំឡុង ៤៨ ម៉ោងបន្ទាប់ពីមានក្តៅខ្លួននោះទេ។




*Figure-8: Dengue detection reported sources in Cambodia 2019*